ភ្នំពេញ , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០៣ អនក្រ ស្តីពីការឈប់សំរាក
# ការងាររបស់មន្ត្រី រដ្ឋការនិយោជិត និង កម្មកររដ្ឋ
# នៅរៀងរាល់ល្ងាចថ្ងៃសៅរ៍

*****

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសំណើរបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១០ លស ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៣

## សំរេច

**មាត្រា ១ :** ត្រូវបានអនុញ្ញាតអោយ មន្ត្រីរដ្ឋការ និយោជិត និង កម្មកររដ្ឋឈប់សំរាកការងារនៅរៀងរាល់ល្ងាចថ្ងៃសៅរ៍ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន និងអភិបាលគ្រប់ខេត្តក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានិង ចុះហត្ថលេខាតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

ព្រះហស្តលេខា | ហត្ថលេខា

**សម្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន**

www.pheakdeylaw.com